01565457
Declassified to Public
20 December 2018

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
14 / 03 / 2018
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E378/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សម្ងាត់ / Confidential / Confidentiel

ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៨

**ជូនចំពោះ** លោក Isaac Endeley ប្រធានអង្គភាព
គាំពារ ការការពារក្តី (អ.គ.ក.)

**ពី** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
ភាគីទាំងអស់នៃសំណុំរឿង ០០២

**កម្មវត្ថុ** ឋានៈរបស់សហមេធាវីអន្តរជាតិ ក្នុងសំណុំរឿង ០០២/០២

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលលិខិតមួយច្បាប់ (ជាភាសាហូឡង់) ពីប្រធានគណៈមេធាវីនៃទីក្រុងអាំស្ទែដាំ ឆ្លើយតបនឹងការបញ្ជូនព័ត៌មានពីអង្គជំនុំជម្រះសាលាដំបូងទៅគណៈមេធាវីទីក្រុងអាំស្ទែដាំ ស្តីអំពីការប្រព្រឹត្តិរបស់សហមេធាវីអន្តរជាតិ លោក Victor Koppe នៅក្នុងអំឡុងដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះសាលាដំបូងសូមទាញចំណាប់អារម្មណ៍របស់លោកប្រធានទៅលើលិខិតដែលបានភ្ជាប់មកជាមួយនេះ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៨ ពីប្រធានគណៈមេធាវី ទីក្រុងអាំស្ទែដាំ ផ្ញើជូនរដ្ឋបាលរបស់ក្រុមប្រឹក្សាវិន័យ ដែលជាផ្នែកមួយនៃខ្លឹមសារលិខិតដែលបានឆ្លើយឆ្លងគ្នានេះ។ ជាពិសេស អង្គជំនុំជម្រះកត់សម្គាល់ទៅលើសម្រង់ខាងក្រោមនេះ៖

> ខ្ញុំសូមជម្រាបលោកស្រីអំពីបណ្តឹងរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (បន្ទាប់ពីនេះទៅហៅថា អ.វ.ត.ក.) ប្រឆាំងនឹងលោក V.L. Koppe ដែលការចោទប្រកាន់មួយចំនួនពាក់ព័ន្ធទៅនឹងរយៈពេលចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ ដែលលោក Koppe បានចុះឈ្មោះក្នុងបញ្ជីមេធាវីទីក្រុងអាំស្ទែដាំ ប៉ុន្តែ

តាមពិតគាត់មានការិយាល័យមេធាវីក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ជាច្រើនឆ្នាំមក ហើយ ហើយមួយចំនួនទៀតពាក់ព័ន្ធទៅនឹងរយៈកាលដែលលោក Koppe នៅមានឈ្មោះជាមេធាវីក្នុងប្រទេសកម្ពុជា ប៉ុន្តែគាត់មិនបានចុះឈ្មោះជាមេធាវីក្នុងប្រទេសហូឡង់។ ហេតុនេះ អនុលោមតាមបទដ្ឋានច្បាប់នៃប្រទេសហូឡង់ គាត់គឺជាអតីតមេធាវីហូឡង់។ (សេចក្តីបញ្ជាក់បន្ថែម)

២. សម្រង់នេះបញ្ជាក់ឲ្យឃើញថា លោក Koppe មិនមែនជាសមាជិកនៃគណៈមេធាវីទីក្រុងអាំស្ទែដាំ តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ មកម្ល៉េះ។ អង្គជំនុំជម្រះយល់ឃើញថា អង្គភាពគាំពារការពារក្តី តម្រូវឲ្យសហមេធាវីអន្តរជាតិនៅ អ.វ.ត.ក. ជាសមាជិកនៃគណៈមេធាវីជាតិនៅក្រៅប្រទេសកម្ពុជា។ ប្រសិនបើមិនបានបំពេញនូវលក្ខខណ្ឌនេះទេ មេធាវីបរទេសមិនអាចប្រកបវិជ្ជាជីវៈជាសហមេធាវីនៅ អ.វ.ត.ក. បានឡើយ ទោះបីជា*មិនយកប្រាក់កម្រៃ*ក៏ដោយ។ អង្គជំនុំជម្រះយល់ឃើញទៀតថា សមាជិកភាពនៅក្នុងគណៈមេធាវីជាតិនៅបរទេស ក៏ជាបុរេលក្ខខណ្ឌមួយផងដែរដើម្បីអាចចុះឈ្មោះបានក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

៣. យោងតាមព័ត៌មានដែលប្រធានគណៈមេធាវីទីក្រុងអាំស្ទែដាំបានផ្តល់ជូននេះ បង្ហាញឲ្យឃើញថា លោក Koppe អាចមិនមានសិទ្ធិតំណាងឲ្យ នួន ជា តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ មកម្ល៉េះ ហើយអាចមិនមានសិទ្ធិតំណាងឲ្យគាត់បានទេ នៅពេលខាងមុខនេះ។

៤. ដោយពិចារណាទៅលើព័ត៌មាននេះ អង្គជំនុំជម្រះសូមឲ្យលោកប្រធានសុំការបញ្ជាក់បំភ្លឺពីលោក Koppe ពាក់ព័ន្ធនឹងឋានៈរបស់គាត់ និងជូនដំណឹងមកអង្គជំនុំជម្រះយ៉ាងយូរបំផុតនៅត្រឹមថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៨ អំពីចំណាត់ការណាខ្លះដែលអង្គភាពគាំពារការការពារក្តីអាចធ្វើឡើងដោយផ្អែកលើព័ត៌មាននេះ។